ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

# ដំណាំម្រេច









រៀបចំដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
នាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

ឧបត្ថម្ភការបោះពុម្ពដោយៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ឆ្នាំ២០១៧










**អាសយដ្ឋាន** : ផ្ទះលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

**ទូរស័ព្ទលេខ** : ០២៣ ២១៥ ៨១៩

០១២ ៥៩ ៤៦ ៧៨

**ទូរសារលេខ** : ០២៣ ២១ ០៩ ៤៨

**Facebook** : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

Department of Agricultural Extension

**គេហទំព័រ** : http://www.maff.gov.kh

# សៀវភៅ

# ស្តីពី

# ដំណាំម្រេច

## រៀបចំដោយ

## នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម សហការជាមួយ
## នាយកដ្ឋានដំណាំឧស្សាហកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម

បោះពុម្ពលើកទី១ ចំនួន ២០០០ ច្បាប់

ឧបត្ថម្ភការបោះពុម្ពដោយ: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រក្សាសិទ្ធដោយ: នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

# សមាសភាពចូលរួមចំណែកផលិតសៀវភៅ
# ស្តីពីដំណាំម្រេច

I. ទីប្រឹក្សាផ្តល់យោបល់:

| | | |
|---|---|---|
| ១. បណ្ឌិត | **ហ៊ាន វណ្ណហាន** | អគ្គនាយកដ្ឋានកសិកម្ម |
| ២. បណ្ឌិត | **ម៉ៅ មីនា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៣. លោក | **ខាន់ សំបាន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ៤. លោក | **ប៉ែន វុទ្ធី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៥. លោក | **គឹម ដារ៉ា** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

II. អ្នករៀបរៀង:

| | | |
|---|---|---|
| ១. លោក | **ផាន ទូច** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |

III. អ្នកស្រាវជ្រាវ:

| | | |
|---|---|---|
| ១. លោក | **ខាន់ សំបាន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ២. លោក | **យិន ច័ន្ទសុធី** | នាយកដ្ឋានដំណាំឧស្សាហកម្ម |

IV. ក្រុមការងារត្រួតពិនិត្យ និងកែសម្រួល:

| | | |
|---|---|---|
| ១. លោក | **ខាន់ សំបាន** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ២. លោក | **យិន ច័ន្ទសុធី** | នាយកដ្ឋានដំណាំឧស្សាហកម្ម |
| ៣. លោក | **ហុង ទ្រី** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| ៤. លោក | **ឈុន សុភ័ក្ត្រ** | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |





## មាតិកា ទំព័រ


១. សេចក្ដីផ្ដើម.................................................................................. ០១
២. ស្ថានភាពទូទៅដំណាំម្រេច.......................................................... ០១
    ២.១ ស្ថានភាពដំណាំម្រេចនៅលើពិភពលោក ............................... ០១
    ២.២ ស្ថានភាពដំណាំម្រេចនៅប្រទេសកម្ពុជា..................................០២
    ២.៣ សារៈប្រយោជន៍នៃដំណាំម្រេច............................................ ០៧
    ២.៤ ពូជដំណាំម្រេចនៅកម្ពុជា ..................................................០៨
៣. បរិស្ថានវិទ្យា......................................................................................០៩
៤. លក្ខណៈរូបសាស្ត្រនៃដំណាំម្រេច...................................................... ១១
    ៤.១ ស្លឹក ៖...............................................................................១១
    ៤.២ ផ្កា ៖.................................................................................១១
    ៤.៣ ផ្លែ ៖.................................................................................១១
៥.បច្ចេកទេសដាំដុះ................................................................................ ១២
    ៥.១ ការជ្រើសរើសពូជ............................................................. ១២
    ៥.២ វិធីសាស្ត្របណ្ដុះកូនម្រេច........................................................១២
    ៥.៣ វិធីសាស្ត្រដាំដុះ..................................................................... ១៥
    ៥.៤ របៀបថែទាំ..........................................................................១៨
៦. ការដាំឱ្យឡើងជន្លង់រស់.................................................................... ២១
៧. ការប្រមូលផលម្រេច.........................................................................២២
៨. សត្វល្អិត និងជំងឺ.............................................................................២៥
៩. បច្ចេកវិទ្យា........................................................................................ ២៦

## ១. សេចក្តីផ្តើម

ដំណាំម្រេចជាប្រភេទរុក្ខជាតិវល្លិ ស្ថិតក្នុងអម្បូរ (Pipperacee) ហើយត្រូវបានគេដាំដើម្បីយកផ្លែ និងហាលសម្ងួតសម្រាប់ជាគ្រឿងទេស និងគ្រឿងក្តៅក្នុងការបង្កើនរសជាតិនៃអាហារ។ ម្រេចមានដើមកំណើត មកពីប្រទេសឥណ្ឌាភាគខាងត្បូង ហើយត្រូវបានគេយកមក ដាំរហូតដល់កន្លែងដទៃទៀតនៅក្នុងតំបន់ត្រូពិក។ ម្រេចគឺជាគ្រឿងទេសមួយ ក្នុងចំណោមគ្រឿងទេសជាច្រើន ដែលត្រូវគេបានដាក់បញ្ចូលបន្ថែមនៅក្នុងអាហារអឺរ៉ុប សម្រាប់ជួយដល់សុខភាពទៀតផង។ ពាក់ព័ន្ធនឹងដំណាំម្រេចនេះ បច្ចុប្បន្នប្រទេសវៀតណាម គឺជាអ្នកផលិត និងនាំចេញធំបំផុតនៅលើពិភពលោក សម្រាប់ផលិតផលម្រេច ។

ដំណាំម្រេចអាចដាំដុះលូតលាស់ល្អ ក្នុងកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំពី ២០០០-២៥០០ មម ឬច្រើនជាងនេះ។ នៅប្រទេសកម្ពុជាយើង ដំណាំម្រេចជាដំណាំឧស្សាហកម្មយ៉ាងសំខាន់ សម្រាប់បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងសេដ្ឋកិច្ចជាតិ។

## ២. ស្ថានភាពទូទៅដំណាំម្រេច

### ២.១ ស្ថានភាពដំណាំម្រេចនៅលើពិភពលោក

ផលិតផលម្រេច ដែលបានផលិតពីប្រទេសជាសមាជិករបស់សហគមន៍ម្រេចអន្តរជាតិចំនួន ៦ប្រទេស រួមមាន ប្រេស៊ីល ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ស្រីលង្កា និងវៀតណាម បានប្រមាណជា ៨៥% នៃផលិផលសរុបទូទាំងពិភពលោក។ ក្នុងនោះទិន្នផលម្រេចទូទាំងពិភពលោក ឆ្នាំ២០១១ ចំនួន ២៥០.៧៨០តោន ដោយទទួលបានទឹកប្រាក់ចំនួន ១.៥៨ ពាន់លានដុល្លារ រីឯឆ្នាំ២០១៣ ទិន្នផលម្រេចមានចំនួន ២៤៩.៥០០តោន បានទទួលទឹកប្រាក់ចំនួន ១.៩ពាន់លានដុល្លារ ចំណែកក្នុងឆ្នាំ ២០១៤ នេះក្នុងរយៈពេល ៦ខែដើមឆ្នាំបានទិន្នផលម្រេច ចំនួន ២៤៧.៥០០តោន ដោយទទួលបានទឹកប្រាក់ចំនួន ២.៤ពាន់លានដុល្លារ ហើយគេសង្ឃឹមថា ទិន្នផលម្រេចនឹងកើនឡើងរហូតដល់ ៣៥០.០០០តោន ក្នុង១ឆ្នាំ ដោយទិន្នផលកើនឡើង ៥% ក្នុង១ឆ្នាំៗ ជារៀងរាល់ឆ្នាំ។ ដោយឡែកទិន្នផលម្រេចរបស់ប្រទេសវៀតណាម ក្នុងឆ្នាំ២០១៣ មានចំនួន ១៣២.៩៥៥តោន បាននាំចេញទៅលក់នៅប្រទេសចំនួន

១០០ លើពិភពលោក ដោយទទួលបានចំណូលជាទឹកប្រាក់ចំនួន ៩០០លានដុល្លារ ចំណែកក្នុងឆ្នាំ ២០១៤ ក្នុងរយៈពេលតែ ៦ខែដើមឆ្នាំ ទទួលបានចំណូលពីការលក់ផលិតផលម្រេចចំនួន ៧២៦.២លានដុល្លា។

## ២.២ ស្ថានភាពដំណាំម្រេចនៅប្រទេសកម្ពុជា

ការកត់សម្គាល់ អំពីដំណាំម្រេចនៅកម្ពុជា ដែលមានមកយូរជាងគេ គឺមាននៅក្នុងសារណារបស់លោក ជីវតាក្វាន់ (១២៩៥-១២៩៧)។ នៅសម័យនោះម្រេចមានច្រើនប្រភេទ ដុះឯងក្នុងព្រៃ ក្នុងនោះមានប្រភេទខ្លះត្រូវបានគេដាំដុះ។ ក្នុងឥណ្ឌូចិនភាគខាងត្បូង ដំណាំម្រេចទើបតែមាន មិនមែនមានមុនសតវត្សទី១៩ឡើយ។ រវាងឆ្នាំ១៩៤០ ជនជាតិចិនមកពីហៃណាន បានអនុវត្តការដាំដុះដាំម្រេចនៅ ហាទៀង ហើយចេញពីទីនោះមក ទើបគេពង្រីកដំណាំនេះមកកម្ពុជា ដែលស្ថិតនៅក្នុងស្រុកកំពង់ត្រាច និងស្រុកបន្ទាយមាស អស់រយៈកាលយូរបង្គួរ។ ដំណាំម្រេចក៏បានរីកសាយចូលក្នុងខេត្តកំពត នាឆ្នាំ១៨៨៩ (ចប់សម័យអសន្តិសុខ) និងជាពិសេសក្នុងឆ្នាំ១៨៩២ ដែលនៅឆ្នាំនោះ ម្រេចខ្មែរ ត្រូវបានអនុគ្រោះឱ្យរួចពន្ធក្នុងការនាំចូលប្រទេសបារាំង។ ប្រវត្តិនៃម្រេចខ្មែរ គឺពោរពេញទៅដោយព្រឹត្តិការណ៍ផ្សេងៗជាបន្តបន្ទាប់ រួមមានវិបត្តិដោយលក់មិនដាច់ម្តង មានតម្រូវការខ្ពស់ឡើងវិញយ៉ាងសកម្ម។ ព្រឹត្តិការណ៍នេះបណ្តាលមកពីការប្រែប្រួលខ្លាំងពេក នៃតម្លៃម្រេចលើទីផ្សារអន្តរជាតិ។ រាជរដ្ឋាភិបាលបានទប់ទល់ដោយបានដាក់ចុះនូវវិធានការណ៍ជាបន្តបន្ទាប់ ទាក់ទងខាងផ្នែក សេដ្ឋកិច្ច និងពន្ធដារ។ ការបំបាត់ពន្ធដារ (១៨៩២) ការកំណត់បរិមាណ និងពេលវេលានាំចេញ (១៩០២-១៩២៨) ការកម្រិតការដាំដុះមិនឱ្យលើចំនួន (ពី ១៩៣៥ ដល់ ១៩៤៩) ការដាក់ពន្ធអាករធ្ងន់។ ចៃដន្យនៃជំងឺតាំងពីឆ្នាំ ១៩៣៩ បានបន្ថែមទម្ងន់ទៅលើបុព្វហេតុសេដ្ឋកិច្ចនៃការដើរថយក្រោយ និងការបោះបង់ចោលចម្ការចាស់ម៉្យាង និងម៉្យាងទៀតបានជំរុញអ្នកដាំ ឱ្យទៅរកដីថ្មីនៅភាគខាងលិច។ ការថយចុះនៃចំនួនដើមម្រេចដែលមានយ៉ាងច្បាស់ពីឆ្នាំ១៩៣០ ទៅ ១៩៤០ បានត្រូវជំរុញថែមទៀត ដោយការបញ្ឈប់ការនាំចេញពីឆ្នាំ ១៩៤២ ដល់ ១៩៤៥ ចំណុចទាបបំផុតនៃបន្ទាត់ខ្សែកោង "ក្រាហ្វិក "មានពីឆ្នាំ១៩៤៩ ដល់ ១៩៥៥ ក្នុងរយៈពេលនោះ ចំនួនដើមម្រេចចុះមក

នៅក្រោម១លាន ដើម ទល់នឹង ១.៩៤៤.០០០ ក្នុងឆ្នាំ១៩៤៤, ២.៦៤៧.០០០ ក្នុងឆ្នាំ១៩៣៧, ៣.៨០០.០០០ ក្នុងឆ្នាំ ១៩២៧, ៤.៦០០.០០០ក្នុងឆ្នាំ១៩០២។ ចាប់ពីពេលនោះមកផលិតកម្មម្រេច បានរីកចម្រើនខ្លះៗវិញ នៅជុំវិញឈូងសមុទ្រ កំពង់សោម ក្នុងឆ្នាំ១៩៦៧ មានចម្ការម្រេច ៧០០ ហិកតា ក្នុងនោះ ៤៥០ហិកតា កំពុងផ្តល់ផល។ ការនាំចេញជាមធ្យមក្នុងកំឡុង ១០ឆ្នាំចុង ក្រោយនេះ ដែលមាន ១.២០០តោន នាំឱ្យម្រេចជាប់ចំណាត់ថ្នាក់លេខ៤ ឬលេខ៥ ទៅតាមឆ្នាំនីមួយៗ ចំពោះតម្លៃផលិតផលកសិកម្មនានាដែលបាននាំចេញ។

បណ្តាមូលដ្ឋានសំខាន់ៗនៃផលិតកម្មដំណាំម្រេច មានការអភិវឌ្ឍន៍ជាបន្ត បន្ទាប់ដូចជាក្នុងស្រុកកំពង់ត្រាច កំពត វាលរេញ ខេត្តព្រះសីហនុ។ចម្ការម្រេចថ្មីៗ សព្វថ្ងៃនេះរីកសាយទៅក្រុងកំពង់សោម និងក្នុងខេត្តកោះកុង។ ពិសេសបានធ្វើការ ការសាកល្បងពង្រីកទៅលើដីក្រហម នៃខេត្តកំពង់ចាមក្នុងឆ្នាំ១៩៥០-១៩៥៣។

ក្នុងឆ្នាំ១៩៦០ផ្ទៃដីដាំដុះដំណាំម្រេចប្រមាណជា៨៦០ហ.ត ហើយបរិមាណផល ២៥២៩ តោន ឆ្នាំ១៩៧៩-១៩៩៣ ផ្ទៃដីដាំដុះដំណាំម្រេចបានដាំឡើងវិញប្រមាណ ជា ២៧៧ ហ.ត នៅ ខេត្តកំពត ព្រះសីហនុ កោះកុង តាកែវ និងកំពង់ចាម ចាប់ពីឆ្នាំ ២០០០មកទីផ្សារម្រេចមាន តម្លៃកសិករចាប់ផ្តើមដាំដុះដំណាំម្រេចឡើងវិញ ធ្វើឱ្យ ផ្ទៃដីដាំដុះដំណាំម្រេចមានការកើន ឡើងរហូតដល់សព្វថ្ងៃ។

## តារាងផ្ទៃដីដាំដុះ និងបរិមាណផលម្រេច ២០១០-២០១៧

| ឆ្នាំ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ |
|---|---|---|---|---|---|---|---|---|
| ផ្ទៃដី(ហត) | ៨៦១ | ៨៧៩ | ១,៤៤៤ | ២,២៧៩ | ២,៦៥៣ | ៤,៦៤៥ | ៦,១២៤ | ៦,៦៧៨ |
| បរិមាណផល(ត) | ១,២៥០ | ១,៤៥០ | ៥,៤០០ | ៦,០០០ | ៧,៥០០ | ៩,៨៤៥ | ១១,៨១៩ | ២០,០៥៤ |

## ក្រាហ្វិកផ្ទៃដីដាំដុះ និងបរិមាណផលម្រេច ២០១០-២០១៧




## តារាងផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងបរិមាណផល របស់ដំណាំម្រេច ឆ្នាំ២០១៥

| ល.រ | ខេត្ត-ក្រុង | ២០១៥ | | |
|---|---|---|---|---|
| | | ផ្ទៃដីដាំដុះ សរុប( ហ.ត ) | ផ្ទៃដីប្រមូលផល ( ហ.ត ) | បរិមាណផល សរុប( តោន ) |
| ១ | បាត់ដំបង | ៣៤ | ១៦ | ៤៥ |
| ២ | កំពង់ចាម | ៧៤ | ៣០ | ១២០ |
| ៣ | កំពង់ស្ពឺ | ១០ | ៤ | ១០ |
| ៤ | កំពង់ធំ | ៦២ | ១៣ | ១៩ |
| ៥ | កំពត | ១២៥ | ២៩ | ៤៦ |
| ៦ | កោះកុង | ១១៨ | ៥១ | ១២៨ |

| | | | | |
|---|---|---|---|---|
| ៧ | ក្រចេះ | ៤៥២ | ៨៧ | ៦០០ |
| ៨ | មណ្ឌលគិរី | ២៣៥ | ២៣ | ៦១ |
| ៩ | ព្រះវិហារ | ៤១ | ៤១ | ៩០ |
| ១០ | ពោធិសាត់ | ១០៥ | ២២ | ៨៨ |
| ១១ | រតនៈគិរី | ៤០៧ | ១០៣ | ២៨៩ |
| ១២ | សៀមរាប | ៧៦ | ៤០ | ៧០ |
| ១៣ | ព្រះសីហនុ | ៦១ | ១៧ | ៦៧.៥ |
| ១៤ | ស្ទឹងត្រែង | ៨ | ៥ | ១៣ |
| ១៥ | តាកែវ | ២០ | ២០ | ៣០ |
| ១៦ | ឧត្តរមានជ័យ | ៨ | - | - |
| ១៧ | កែប | ៩០ | ៥ | ៦ |
| ១៨ | ប៉ៃលិន | - | - | - |
| ១៩ | ត្បូឃ្មុំ | ២,៧១៩ | ១,១៦៦ | ៨១៦២ |
| សរុប | | ៤,៦៤៥ | ១,១៧២ | ៩,៨៤៥ |

តារាងផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងបរិមាណផលដំណាំម្រេច ដាំដុះ១៩ ខេត្ត ឆ្នាំ២០១៦

| ល.រ | ខេត្ត | ផ្ទៃដីដាំដុះ (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | បរិមាណផល (តោន) |
|---|---|---|---|---|
| ១ | ត្បូងឃ្មុំ | ២,៧៦២ | ១,២០៥ | ៨,៥៦៦ |
| ២ | រតនគិរី | ៧៧២ | ៣៥៣ | ៩០២ |
| ៣ | ក្រចេះ | ៦៥៧ | ១៥៦ | ៩២០ |
| ៤ | មណ្ឌលគិរី | ៤៧២ | ៧៨ | ២០៥ |
| ៥ | ព្រះវិហារ | ២៦៦ | ១០២ | ២២៦ |
| ៦ | កំពត | ១៩៧ | ៤៧ | ៨៧ |

| | | | | |
|---|---|---|---|---|
| ៧ | កំពង់ចាម | ១៩៤ | ៤៤ | ១៧៨ |
| ៨ | ពោធិសាត់ | ១៥២ | ៦១ | ១៥២ |
| ៩ | សៀមរាប | ១៣៥ | ៤០ | ៧៩ |
| ១០ | កែប | ១១០ | ១៧ | ៩០ |
| ១១ | កំពង់ធំ | ៩៦ | ១៨ | ២៧ |
| ១២ | បាត់ដំបង | ៨៥ | ៣២ | ៨៩ |
| ១៣ | ព្រះសីហនុ | ៦៥ | ៥៥ | ៨៣ |
| ១៤ | កោះកុង | ៦៣ | ៣៥ | ៧១ |
| ១៥ | តាកែវ | ៤៣ | ៣៩ | ១១៥ |
| ១៦ | កំពង់ស្ពឺ | ១៥ | ៥ | ១២ |
| ១៧ | ប៉ៃលិន | ១៥ | ២ | ៣ |
| ១៨ | ឧត្តរមានជ័យ | ១៥ | - | - |
| ១៩ | ស្ទឹងត្រែង | ១០ | ៥ | ១៤ |
| សរុប | | ៦,១២៤ | ២,២៩៤ | ១១,៨១៩ |

តារាងផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងបរិមាណផលដំណាំម្រេច ឆ្នាំ២០១៧

| ល.រ | ខេត្ត-ក្រុង | ស្ថិតិម្រេច ឆ្នាំ២០១៧ | | |
|---|---|---|---|---|
| | | ផ្ទៃដីដាំដុះ សរុប(ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | បរិមាណផល សរុប(តោន) |
| ១ | បាត់ដំបង | ១២០ | ១២០ | ១៧៨ |
| ២ | កំពង់ចាម | ១៨៧ | ៩២ | ៤៦៦ |
| ៣ | កំពង់ស្ពឺ | ១៥ | ៥ | ១២ |
| ៤ | កំពង់ធំ | ៩៦ | ១៨ | ២៧ |
| ៥ | កំពត | ៣៧៣ | ៧០ | ១២៣,៩ |

| | | | | |
|---|---|---|---|---|
| ៦ | កោះកុង | ៩០.២ | ៣៤.៧ | ៧១.២៦ |
| ៧ | ក្រចេះ | ៧២៨ | ៧២៥ | ១,២១៦ |
| ៨ | មណ្ឌលគិរី | ៥២៣ | ២២០ | ៤៧៣ |
| ៩ | ព្រះវិហារ | ៣១២ | ២៥០ | ៥៥០ |
| ១០ | ពោធិសាត់ | ១៥៥.៣ | ៦១ | ១៥២ |
| ១១ | រតនគិរី | ៩៧១.១០ | ៤៧០.៨០ | ១,២៣៤.០៤ |
| ១២ | សៀមរាប | ១៣៥ | ៤០ | ៨០ |
| ១៣ | ព្រះសីហនុ | ៧១ | ៥៥.៥ | ៨៥ |
| ១៤ | ស្ទឹងត្រែង | ៨ | ៨ | ១៤,៤ |
| ១៥ | តាកែវ | ២២ | ២២ | ៧៤ |
| ១៦ | ឧត្តរមានជ័យ | ១៥ | ដាំថ្មី | ដាំថ្មី |
| ១៧ | កែប | ១២២.៥០ | ១២២.៥០ | ៣៣៤,៣៤ |
| ១៨ | ប៉ៃលិន | ១៤ | ២ | ៣ |
| ១៩ | ត្បូងឃ្មុំ | ២,៧២០ | ២,៧២០ | ១៤,៩៦០ |
| សរុប | | ៦,៦៧៨ | ៥,០៣៧ | ២០,០៥៤ |

## ២.៣ សារៈប្រយោជន៍នៃដំណាំម្រេច

គ្រាប់ម្រេច និងប្រេងម្រេចបានផ្តល់ផលប្រយោជន៍ជាច្រើនចំពោះសុខភាពសម្រស់ និងជាថ្នាំសម្រាប់ព្យាបាលដ៏ចម្បងមួយចំនួនដូចខាងក្រោមៈ

### ២.៣.១ សារៈប្រយោជន៍នៃគ្រាប់ម្រេច

✔ ចំពោះសុខភាពៈ គឺជួយប្រឆាំងនឹងជាតិអុកស៊ីតកម្ម និងបាក់តេរី ដែលជួយដល់ការរំលាយអាហារពិសេសក្រពះ និងពោះវៀន។ ម៉្យាងទៀត បានជួយរាំងមិនឱ្យកើតនូវ ជាតិអាស៊ីតហាយត្រូក្លរីដក្នុងក្រពះ។ មិនតែប៉ុណ្ណោះ បានជួយបញ្ចេញញើសជួយបំផ្លាញនូវសារធាតុធ្វើឱ្យធាត់ កាត់បន្ថយជាតិខ្លាញ់ រក្សាសមតុល្យក្នុងរាងកាយផ្តល់កម្លាំងថាមពល កាត់បន្ថយការញៀនបារី ជួយស្រូបយកសារធាតុមានប្រយោជន៍

ចំពោះរាងកាយ ដូចជា វីតាមីនបេ កាល់ស្យូម បេតាការ៉ូអ៊ីន កាត់បន្ថយការរលាកក្រពះ ហើយប្រឆាំងជាមួយសារជាតុ ដែលបង្កឱ្យកើតជាជំងឺមហារីកផងដែរ។

✔ ចំពោះសម្រស់ៈ មានដូចជា ការកើតមុន សុខភាពស្បែក និងជួយការពារស្បែកពីជំងឺមហារីក។

✔ ជាថ្នាំព្យាបាល ជំងឺពុកធ្មេញ ជំងឺឈឺធ្មេញ រោគដំបៅមាត់ កម្ទាត់ចៃ និងអង្គែ ជំងឺស្រែង រោគរមាស់ និងជួយបង្កើនការចងចាំ។

### ២.៣.២ សារៈប្រយោជន៍នៃប្រេងម្រេច

ប្រេងម្រេចគឺគេចម្រាញ់ចេញពីម្រេចទុំ ដើម្បីបំបាត់អាការៈឈឺសន្លាក់ដៃជើង ធ្វើឱ្យចរន្តឈាមរត់បានស្រួល បំបាត់អាការៈផ្តាសសាយ អារម្មណ៍មួរម៉ៅ ជួយសម្រួលដល់ការរំលាយអាហារ ជំងឺស្លឹក ថ្នាំសម្លាប់មេរោគ បន្សាបជាតិពិស ថ្នាំសម្រើប ថ្នាំបញ្ចុះ ថ្នាំបំប៉នកម្លាំង បំបាត់ការហើមពោះ និងការរលាកភ្លើង ប្រឆាំងនឹងបាក់តេរីក្នុងមាត់ និងពោះវៀនធំ ជាំមុខ ជួយស្រូបយកជាតិខ្លាញ់ក្នុងខ្លួន និងធ្វើឱ្យសម្ពាធឈាមដើរស្រួល។ល។

## ២.៤ ពូជដំណាំម្រេចនៅកម្ពុជា

នៅកម្ពុជា គេឃើញមានម្រេចក្នុងស្រុក២ប្រភេទ ម្រេច១ប្រភេទមានស្លឹកធំៗ និងសាច់ចន្លោះថ្នាំងវែងៗ ម្រេចនេះហាក់ដូចជាស្របគ្នាទៅនឹងម្រេចឡាំប៉ុងរបស់ប្រទេសឥណ្ឌូនេស៊ី។ ម្រេច១ប្រភេទទៀត ហៅថាម្រេចកំចាយ ដែលជាឈ្មោះភូមិភាគមួយនៅជិតកំពត មានស្លឹកតូចៗ សាច់ចន្លោះថ្នាំងខ្លីៗ ហើយមានភិនភាគស្រដៀងនឹងម្រេចបង់កានៃប្រទេសឥណ្ឌូនេស៊ី។ ម្រេចកំចាយ ប្រហែលជាស៊ូទ្រាំនឹងភាពរលួយគល់ជាង។ សមត្ថភាពនេះ មានដូចម្រេចបេឡង់តឹង ដែលមានដើមកំណើតពីប្រទេសថៃ ប៉ុន្តែត្រូវបាននាំចូលពីប្រទេសម៉ាដាហ្កាស្កា ក្នុងឆ្នាំ ១៩៤៧ នៅក្នុងពូជជាមួយម្រេចឡាំប៉ុង ដែលមានស្លឹកធំ។ បច្ចុប្បន្ននេះឃើញមានពូជម្រេចមួយចំនួនបាននាំចូលពីប្រទេសជិតខាងគឺពូជ Vinh linh ស៊ីឡានខាវ និងពូជ Pannyure I។

គេដឹងថាដើមម្រេចជាវល្លិ៍រស់បានយូរ ដែលអាចវារឡើងបានខ្ពស់ ប៉ុន្តែក្នុងការដាំដុះ គេរក្សាទុកតែត្រឹម៣,៤ ឬ៥ ម៉ែត្រ ឱ្យឡើងតាមជន្លង់ងាប់ ឬ រស់។ លើដើម

មានលក្ខណៈពិសេស ដោយតាមថ្នាំងនីមួយៗមានដុះឫសសម្រាប់តោងជន្លង់ និងមានចេញមែកមួយដែលផ្តល់ផ្លែ។ ផ្លែវាមានទងដុះជាចង្កោមៗញឹក ពីដំបូងពណ៌បៃតងបន្ទាប់មកលឿង ហើយក្រហមនៅពេលវាទុំ។ ផ្កាជាធម្មតាមានទាំងពីរភេទរួមគ្នា "ញី និងឈ្មោល " ប៉ុន្តែអាចមានតែមួយភេទ ចំពោះដើមណាដែលដុះពីគ្រាប់ឬមានផ្កាញីផ្សេងផ្កាឈ្មោលផ្សេងពីគ្នា គ្មានផលប្រយោជន៍ចំពោះផលិតកម្ម។









នេះជារូបភាពដំណាំដីផ្លីដែលស្ថិតក្នុងអំបូរជាមួយដំណាំម្រេច (អំបូរ Pipperacee)

## ៣. បរិស្ថានវិទ្យា

អាកាសធាតុក្តៅជាគំរូដីជ្រៅ ស្រស់ទឹក ត្រជាក់ក្នុងគ្រប់រដូវ ទាំងអស់នេះជាការទាមទារជាគ្រឹះរបស់ដំណាំម្រេច។ ម្រេចអាចផ្សាំខ្លួនទៅក្នុងតំបន់ក្តៅបើសិនជារដូវ

ប្រាំងមិនខ្លាំងក្លាហួសពេក ដូច្នេះនៅប្រទេសកម្ពុជាភូមិភាគឆ្នេរសមុទ្រគឺ សមស្របបង្គួរខាងផ្នែកអាកាសធាតុ ប៉ុន្តែចំនួនទឹកភ្លៀងច្រើនលើសលប់ក្នុងខែ សីហា-កញ្ញា លើសពី១ម ក្នុងមួយខែ នៅក្រុងកំពង់សោម អាចជាប្រការមិនល្អទៅវិញ។ រដូវប្រាំងក្តៅខ្លាំងពេក ក៏មិនអំណោយផលដល់ដើមម្រេចដែរ ប៉ុន្តែមានប្រយោជន៍មិនផ្ទាល់ ដោយធ្វើឱ្យម្រេចចេញផ្កា និងផ្លែស្រុះគ្នា បើគេដាក់ជីសមស្របនៅដើមរដូវវស្សា។

កត្តាផ្សេងៗនៃអាកាសធាតុ: កំដៅ និងសំណើមបរិយាកាសមធ្យម ខ្ពស់ មិនមានការប្រែប្រួលខ្លាំងជាប្រចាំថ្ងៃ ឬប្រចាំរដូវ អវត្តមាននៃខ្យល់បក់ខ្លាំង ដែលធ្វើឱ្យរបើកដើមម្រេច កត្តាទាំងអស់ នេះជាធម្មតាមាននៅតាមទីទំនាបៗ។ នៅក្នុងធម្មជាតិ ម្រេចជារុក្ខជាតិមានតម្រូវការម្លប់។ ដូច្នេះគេអាចដាំម្រេចក្រោមម្លប់ឈើរស់បាន ប៉ុន្តែក៏គេអាចដាំម្រេចក្រោមកំដៅជាអតិបរមាបានផងដែរ លើកលែងតែពេលម្រេចនៅតូច ជាក់ស្តែង ដូចជាគេបានអនុវត្តនៅកម្ពុជា ដោយប្រើជន្លង់ឈើងាប់ ដើម្បីបង្ខំម្រេចឱ្យឆាប់ផ្លែ។

ចំពោះដីបណ្តាគុណភាពរូបសាស្ត្រត្រូវតែពិនិត្យជាដំបូងបង្អស់ (ទម្រង់រចនាសម្ព័ន្ធ ភាពជ្រាបទឹក សមត្ថភាពបៀមទឹក និងហួតទឹក) ពីព្រោះម្រេចជាដំណាំមិនធន់ទៅនឹងភាពជាំទឹក និងពពួកសត្វដូចអន្ទង់តូចៗ ជំងឺផ្សិត ដែលជាធម្មតា តែងតែមានមកព្រមគ្នាជាមួយនឹងបរិមាណទឹកហួសប្រមាណក្នុងបរិវេណដែលម្រេចចាក់ឫស។

ដូច្នេះដីណាដែលសម្បូរដីឥដ្ឋ រឹង មិនជ្រាបទឹក គឺត្រូវតែជៀសវាង។ ដោយឡែកប្រភេទដីក្រហម ដែលកើតពីសិលាបាសាល់ ឆ្លើយតបសឹងតែសុក្រិត្យចំពោះការទាមទាររបស់ដំណាំម្រេច ប៉ុន្តែភាពច្រោះទឹកខ្លាំងរបស់ដីនោះ គួបផ្សំជាមួយនឹងការឡើងកម្តៅខ្លាំងនៅរដូវប្រាំង ពិសេសលើតំបន់ខ្ពង់រាប ទាមទារជាចាំបាច់ នូវការអនុវត្តបច្ចេកទេសដាំដុះខុសគ្នា ពីបច្ចេកទេសរបស់ខ្មែរអ្នកដាំម្រេច ដោយជន្លង់រស់ ម្លប់ដែលសម្រួលបានដល់ការស្រោចស្រព។

នៅភូមិភាគឆ្នេរសមុទ្រ លើដីដែលជាធម្មជាតិ កើតមកពីថ្មសំលៀង គេធ្វើចម្ការម្រេច នៅតាមជើងភ្នំ ដែលនៅទីនោះជម្រៅដីគឺមានគ្រប់គ្រាន់ ហើយព្រៃដែលនៅជិតៗនោះ អាចផ្តល់ឈើសម្រាប់ធ្វើជន្លង់ និងដីមានជីជាតិសម្រាប់ចាក់ជារង។ ប៉ុន្តែដីមួយចំនួនធំ ច្រើនតែមានជាតិអាស៊ីតច្រើន pH=៤- ៤.៥ ហើយជាពិសេស មានភាគដីខ្សាច់

ម៉ត់ខ្ពស់ពេកដែលនាំ ឱ្យដីឆាប់ហាប់ និងបៀមទឹក ទោះបីនៅលើដីលើកក៏ដោយ។ ការវិភាគលើដីដាំម្រេចមួយកន្លែងនៅកែប ដែលបានរាយការណ៍ដោយម៉ារីណេបង្ហាញឱ្យឃើញភាគម៉ត់ច្រើនណាស់ ប្រហែល ៩៥ភាគរយ ហើយក្នុងដីម៉ត់នេះមានកម្រិតដីខ្សាច់ម៉ដ្ឋខ្ពស់ ប្រហែល៦០ភាគរយ ហើយនឹងធាតុម៉ដ្ឋដទៃទៀត ក្នុងលំដាប់កើនឡើងតាមជម្រៅដី (ដីឥដ្ឋ ៩,៧៦ភាគរយ ពីជម្រៅ0 ទៅ ១៥ស.ម, ១៦,២៤ភាគរយ ពីជម្រៅ ៧៥ ទៅ ១០០ស.ម) ក្នុងស្ថានភាពនេះ ការស្រោចស្រពដែលសំខាន់សម្រាប់ដំណាំពុំអាចធានាបានទេ។

## ៤.លក្ខណៈរូបសាស្ត្រនៃដំណាំម្រេច

### ៤.១ ស្លឹក



ស្លឹកមានរាងដូចផ្លាអាល់ម៉ុន រាងស្មុតួចនៅខាងចុងហើយមានពណ៌បតៃងចាស់ និងភ្លឺនៅខាងលើ និងពណ៌បៃតងស្លេកនៅផ្នែកខាងក្រោម ដែលដុះតំរៀបឆ្លាស់គ្នានៅលើទងម្រេច។

### ៤.២ ផ្កា



ផ្កាចេញជាចង្កោម តាមទងផ្កាដែលត្រូវបានគេស្គាល់ថាជាក្តួរ។ ផ្កាមានពណ៌សទៅបៃតងរាងលឿងពី ៥០-១៥០ ផ្កាបង្កើតបានជាមួយទងផ្កា។

### ៤.៣ ផ្លែ

ផ្លែរាងមូលដូចផ្លែប៊ើរី មានអង្កត់ផ្ចិតរហូតដល់ ៦ មីលីម៉ែត្រ។ នៅពេលដំបូងវាមានពណ៌បៃតង ប៉ុន្តែប្រែជាពណ៌ក្រហមនៅពេលទុំ។

ផ្លែមួយៗមានគ្រាប់មួយ ហើយក្នុងមួយទង ផ្លែមានផ្លែពី ៥០-៦០ផ្លែ។ ផ្លែត្រូវបានគេ បេះនៅពេលវាមានពណ៌បៃតងនិងពេញ វ័យ ដើម្បីផលិតជាម្រេចបៃតង។ នៅពេល ដែលវាចាស់ពេញលេញតែនៅពណ៌បៃតង ភ្លឺ គេយកធ្វើជាម្រេចខ្មៅ និងពេលវាទុំបន្តិច គេផលិតជាម្រេចស (ដែលផ្លែម្រេចត្រូវ បានគេត្រាំទឹក ដើម្បីយកសំបកខាងក្រៅ ចេញ)។



### ៥. បច្ចេកទេសដាំដុះ

ដំណាំម្រេចគេអាចដាំតាមរយៈការ កាត់ទងយកទៅដាំដោយផ្ទាល់និងការកាត់ យកទង ម្រេចមកបណ្តុះនៅថ្នាលបណ្តុះ កូនរួចយកទៅដាំនៅឯចម្ការ។

#### ៥.១ ការជ្រើសរើសពូជ

ទងម្រេចដែលយើងយកមកដាំត្រូវមានអាយុយ៉ាងតិច១ឆ្នាំ ហើយមានដុះឫស ខ្ចីគ្រប់ថ្នាំងទាំងអស់ និងមានមែកគ្រប់ថ្នាំង ហើយគ្មានកើតជំងឺ និងជាពូជដែលផ្តល់ ទិន្នផលខ្ពស់ ព្រមទាំងមានតម្រូវការច្រើននៅលើទីផ្សារ មានទងប្រវែងពី ៥០ ទៅ ៦០ ស.ម មានថ្នាំងញឹក ចន្លោះថ្នាំងនីមួយៗមានប្រវែង ១០ស.ម។ ទងដែលកាត់ចេញពី ចម្ការ ត្រូវយកទៅដាំមិនឱ្យលើសពី ៤៨ ម៉ោងឡើយ ដោយត្រូវរៀបចំទុកដាក់ឱ្យបាន សមស្របតាម លក្ខណបច្ចេកទេស។

#### ៥.២ វិធីសាស្ត្របណ្តុះកូនម្រេច

#### ៥.២.១ ការដាំម្រេចសម្រាប់យកទង

យើងត្រូវរៀបចំថ្នាលបណ្តុះកូនម្រេចសម្រាប់យកទង ក្នុងនោះត្រូវរៀបចំរោង ការពារកម្តៅ ហើយរៀបចំជន្លង់សម្រាប់ម្រេចវារឡើង ដោយគេធ្វើពីចង់ប្លាស្ទីក ឬឈើ

ឬលើកជារង ដែលធ្វើពីចំបើង នៅពេលកូនម្រេចទាំងនោះអាយុបាន ១ឆ្នាំ ទើបគេកាត់យកទៅដាំ ឬក៏បណ្តុះនៅថ្នាលបណ្តុះកូន ដោយទុកគល់ សម្រាប់ការដុះលូតសាល់ជាថ្មី ដើម្បីយកទងទៅប្រើប្រាស់នាឆ្នាំបន្ទាប់។









### ៥.២.២ ការបំបៅ ឬផ្សាំម្រេច

"ការដាំ "ដោយផ្សាំមែក ដើម្បីបានកូនមានឫសច្រើន និងសាកមែក ដែលកាត់យក ពីដើមសម្បូរផ្លែ។ បច្ចេកទេសសាកពីរបែប បានត្រូវធ្វើឡើងៈ

ការសាកដោយសៀតមែកក្នុងរន្ធចំហៀង " J. Carre " និងការសាកផ្គាបមែក" ប្រើនៅតណ្ហា " ។






### ៥.២.៣ ការបណ្តុះកូនម្រេចក្នុងថ្នាល

ដំបូងត្រូវរៀបចំរោង និងថ្នាលបណ្តុះកូនម្រេចជាមុនសិន ទើបចាប់ផ្តើម កាត់ទងម្រេច ដែលមានសុខភាពល្អ និងជាពូជផ្តល់ទិន្នផលខ្ពស់ ពីថ្នាលបណ្តុះកូនម្រេចសម្រាប់យកពូជ ឬពីដើមម្រេច ដែលយើងដាំតាមចម្ការមានអាយុរយៈពេល១ឆ្នាំ ដែលមានប្រវែងពី ១,៨ម-២,៧ម បន្ទាប់មកយកមែកពូជទាំងនោះមកកាត់ ជាង១ថ្នាំង ឬ ២ថ្នាំង ឬ ៣ទៅ៤ថ្នាំង រួចយកមកត្រាំទឹក រយៈពេលពី ១-២ម៉ោង មុនយកទៅដាំនៅក្នុងថង់ប្លាស្ទីកទំហំ ១២,៥សមx ២០សម ដែលបានច្រកដីមានជីជាតិលាយជាមួយផេះអង្កាមសម្រាប់បណ្តុះកូន ហើយទើបស្រោចទឹក និងធ្វើការថែទាំកូនម្រេចទាំងនេះរហូតកូនម្រេចដុះលូតលាស់បានល្អមុនយកទៅដាំនៅតាមចម្ការ។












## ៥.៣ វិធីសាស្ត្រដាំដុះ

### ៥.៣.១ ការរៀបចំដី

ដីត្រូវភ្ជួររាស់ឱ្យបានជ្រៅគឺចាប់ពី ៣០ទៅ៤០សម និងឱ្យបានពី ២ទៅ៣សារ ហើយរាស់បំបែកឱ្យបានម៉ត់ល្អ ព្រមទាំងប្រមូលស្មៅ និងកំទេចកំទីចេញឱ្យអស់ពីចម្ការ ដើម្បីងាយស្រួលដាំដុះម្រេច ក៏ដូចជាចៀសផុតពីការបំផ្លាញពីពពួកសត្វល្អិត និងជំងឺផ្សិតផ្សេងៗ។ ត្រូវរាស់ពង្រាបដីឱ្យបានរាបស្មើ ដើម្បីផ្តល់លទ្ធភាពនៃការដុះ

លូតលាស់ដំណាំម្រេច និងងាយស្រួលបញ្ចូលទឹកស្រោចស្រពនៅរដូវប្រាំង ហើយបង្ហូរទឹកចេញនៅរដូវភ្លៀងធ្លាក់ជោគជាំ។លើកដីពូនរងកម្ពស់ពី១៥ទៅ២០ស.មដែលមានទំហំពី ១ម ទៅ ១,២ម ដើម្បីទុកសម្រាប់ដាំ ព្រមទាំងបោះបង្គោលកូនឈើតូចៗនៅលើរងដែលបានលើកទៅតាមចន្លោះរង និងចន្លោះគុម្ពដែលត្រូវដាំដើម្បីជីកឬខួងរណ្តៅ ដាំដុះ។ចំណែកឯចន្លោះរង និងចន្លោះគុម្ពម្រេចដែល គេនិយមដាំមាន ២ម x ២ម ឬ ២,២ម x ២,២ម ឬ២,៥ម x ២,៥ម អាស្រ័យទៅតាមស្ថានភាព និងប្រភេទដី។

### ៥.៣.២ របៀបដាំ

#### ៥.៣.២.១ ការដាំដោយកាត់ទងដាំ

ជាទូទៅការដាំដំណាំម្រេចដែលទទួលបានលទ្ធផលល្អ ត្រូវអនុវត្តដាំចាប់ពីខែកក្កដា និងសីហា។មែកពូជគេកាត់យកមែកដែលមានអាយុ១ឆ្នាំ ដុះតាមគល់ចាស់ដែលគេដាំពី១ឆ្នាំមុនឬយកពីថ្នាលបណ្តុះកូនម្រេច។ មែកមួយប្រវែង១,៨០មទៅ២,៧០ម អាចកាត់បាន៣កំណាត់ដែលមួយកំណាត់មានថ្នាំងពី៥ទៅ៦ថ្នាំង( ៥០ទៅ៦០សម ) ហើយលើមែកកំណាត់នីមួយៗតម្រូវកាត់មែកតូចៗចេញឱ្យអស់ ទុកតែមែកតូចៗ២ខាងចុង ។ ហើយមុនដាំត្រូវត្រាំទងម្រេចក្នុងទឹក រយៈពេលពី ១ទៅ២ម៉ោង ដើម្បីឱ្យទងមានលទ្ធភាពដុះឫសថ្មីៗបានល្អ។ ត្រូវជីករណ្តៅលើខ្នងរងមានទំហំ ០,៤ម x ០,៤ម x ០,៥ម ដោយដាំ ២ទងក្នុង១រណ្តៅ ហើយកប់ជម្រៅ ៤ទៅ៥ថ្នាំង ទៅក្នុងដីពោលគឺមែកពូជនេះគេដាំពីរទងក្នុងមួយរណ្តៅ ត្រង់ឡើងលើចម្ងាយ ៥ស.ម ពីជន្លង់ និងឃ្លាតពីគ្នាប្រហែល ១០ស.ម ដាក់ឫសបែរទៅជន្លង់ កប់ទងនោះទុកតែ ២ថ្នាំងខាងលើ។ ក្រោយពីបានលុបដី និងជាន់បង្ហាប់ឱ្យណែន គេរៀបចំធ្វើកំពែង។ ចំនួនដើមក្នុង ១ហិកតា ពី ១៦០០ជន្លង់ ទៅ២៥០០ជន្លង់ វាអាស្រ័យទៅលើចន្លោះរង និងចន្លោះគុម្ព ដែលបានដាំ។ បន្ទាប់ពីដាំរួចត្រូវគ្របស្លឹកឈើ ឬសំណាញ់ការពារកម្ដៅដើម្បីការពារកម្ដៅថ្ងៃនៅកន្លែង ដែលបានដាំ។ ក្រោយរយៈពេលពី ៣ទៅ៤ខែ ជាពេលដែលយើងពិនិត្យមើលថាតើ ដំណាំម្រេចមានការដុះលូតលាស់ល្អហើយឬនៅ។ ត្រូវដាក់ជន្លង់ឈើខ្លឹមរឹងមាំ ដែលមានអង្កត់ផ្ចិតពី ១០ទៅ២០ស.ម តាមបណ្តាគុម្ពម្រេចនីមួយៗ បើសិនជាប្រើឈើជន្លង់មិនល្អ អាចជួបការលំបាកក្នុងការប្តូរជន្លង់ពេលម្រេច

កំពុងដុះលូតលាស់ល្អ។








### ៥.៣.២.២ ការដាំដោយកូនបណ្ដុះក្នុងថង់

ការដាំដុះដោយកូនម្រេចបណ្ដុះក្នុងថង់មានលក្ខណៈងាយស្រួលក្នុងការដាំជាងការដាំដោយទង ដោយកូនម្រេចបានដុះលូតលាស់រួចហើយ តែពេលដាំការពារកុំឱ្យបែកដីក្នុងថងដែលអាចធ្វើឱ្យកូនម្រេចអន់ ឬងាប់ រីឯរបៀបដាំគឺប្រហាក់ប្រហែល និងការដាំដោយទងដែរ។







## ៥.៤ របៀបដាំ







ត្រូវជម្រះស្មៅធ្វើឱ្យបានច្រើនសារពេលឃើញស្មៅដុះច្រើន ដែលជាហេតុធ្វើឱ្យម្រេចអន់ ការជម្រះស្មៅត្រូវធ្វើពី ២ទៅ៣សារ ក្នុងរដូវប្រាំង និងពី៤ទៅ៥សារក្នុងរដូវវស្សារ ។ ត្រូវកាប់ ឬ ភ្ជួរពូនគល់ម្រេចឱ្យបាន២ដងក្នុង១ឆ្នាំគឺដើមរដូវភ្លៀង(ឧសភា-មិថុនា) និងចុងរដូវភ្លៀង(តុលា-វិច្ឆិកា)។ ចាប់ពីរដូវប្រាំងទី១ ការចាក់បន្ថែមដីថ្មី (ដីនៅ)ពី ៣ទៅ៤អំរែក ក្នុងម្រេច១គុម្ព ដោយធ្វើ២ដងក្នុង១ឆ្នាំ គឺនៅដើមនឹងចុងរដូវភ្លៀង ដើម្បីបង្កើនជីជាតិដី និង ការលូតលាស់ឫសខាងលើនៃដើមម្រេច។ កាចាក់ដីបន្ថែមគឺច្រើនអនុវត្តន៍នៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តកំពត ព្រះសីហនុ កោះកុង តាកែវ និងកំពង់ស្ពឺ។

បន្ទាប់ពីដាំបានរយៈពេលពី៤ទៅ៥ខែគេឃើញដើមម្រេចនីមួយៗដុះចេញពីទងទាំង២ ជាបួនទងហើយគេចងទងម្រេចទាំង៤ ផ្តោបទៅនឹងជន្លង់ត្រង់កន្លែងមានថ្នាំង គេធ្វើយ៉ាងនេះ តាមលំដាប់លំដោយដែលវាលូតលាស់ ខ្សែចំណងគេយកវល្លិ៍ខ្លែង (Pauhinia)។ ការចងត្រង់ កន្លែងមានថ្នាំងសំរួលឱ្យឫសងាយតោងជន្លង់និងឱ្យមែកផ្តល់ផ្លែលូតលាស់បានល្អ។

ក្នុងរយៈពេល ២ឆ្នាំ ការងារថែទាំត្រូវធ្វើជាប់ជានិច្ចៈ

- ស្រោចទឹក
- យកម្លប់ចេញ ក្រោយពី ៦ខែ
- លប់កំពែងនៅរដូវវស្សា និងធ្វើឡើងវិញនៅរដូវប្រាំង
- ដាក់ជីម្តង (ខែឧសភា-មិថុនា) ឬជាពីរដង (តុលានិងវិច្ឆិកា)។ ក្នុងម្រេចមួយដើម ២បង្គីរដី កំប៉ុស្ត ២បង្គីរដីព្រៃ ឬជីគីមី
- ចាប់សត្វកំពូងដែលស៊ីស្លឹក
- ការបរបោសអង្កែល បេះផ្កាចោលរហូតដល់ឆ្នាំទី៣
- ឆ្នាំទីពីរផ្លាស់ជន្លង់បណ្តោះអាសន្ន ដាក់ជន្លង់ស្ថាពរជំនួស កូនឈើប្រវែង ៥ម អង្កត់ផ្ចិត ១០ទៅ១៥ស.ម បកសំបកចេញ។ នៅក្នុងអំឡុងខែ មិថុនា-កក្កដា កូនម្រេច អាយុ ១ឆ្នាំ ត្រូវបេះចេញពីជន្លង់និងកាត់ចោលត្រង់កម្ពស់ ១៥ឬ២០ស.ម ពីដី។

ដើមម្រេច ដែលកាត់នេះ ផ្តល់មែកពូជសម្រាប់ពង្រីកចម្ការ ឬសម្រាប់លក់។

ជន្លង់ឈើងាប់មានតែតួនាទីមេកានិកសម្រាប់ជាគ្រឿងទប់ដូច្នេះគេជ្រើសរើសប្រភេទឈើរឹង មិនពុក សត្វល្អិតមិនសូវស៊ី ជាពិសេសសត្វកណ្ដៀរ។ ឈើដែលល្អជាងគេ:

- ច្រម៉ាស់ Vatica astrotricha Dipterocarpee
- ផ្ចឹក Shorea obtusa Dipterocarpee
- សុក្រំ Xylia dolabriformis Loguminouse
- នាងផ្អែក Cyadonaphne Combretacee
- ស្រគុំ Payena elliptica Sapotacee
- ព្រូស Garcinia ferra Guttifere
- ស្តៅភ្នំ Aglaia baillonii Meliacee
- មៀនព្រៃ Le Longanier sauvage ស្មាច់ Le Melaleuca ម៉ាក់ប្រាង Le Bovea ក៏មានគេប្រើដែរ ប៉ុន្តែពុំសូវជាប់បានយូរទេ។ ជន្លង់ល្អជាប់បានជាមធ្យម ១០ ឆ្នាំ ការផ្លាស់ជន្លង់ជាការងារត្រូវធ្វើដោយហ្មត់ចត់។ ដូច្នេះដំណាំម្រេច ប្រើប្រាស់ជន្លង់ច្រើនណាស់ ការកាប់ឈើធ្វើជន្លង់នាំឱ្យវាលព្រៃឈើផងដែរ។

ឆ្នាំទី៣ ខែមិថុនា ជារដូវម្រេចផ្កា ដោយសារគេដាក់ជី គេទុកតែផ្កាណាដែលនៅត្រឹម ១-៣ ចុះមកក្រោម ផ្កានេះឱ្យផលអាចបេះបានក្នុងរដូវប្រាំងជាបន្ទាប់។ ក្រោយពីបេះផ្កានិងផ្លែខាងលើចោលហើយ គេត្រូវចាប់ផ្ដើមបាញ់ថ្នាំសម្លាប់សត្វល្អិត ( le tigre de poivrier ) ដែលដង្កូវរបស់វាតែងតែទិចពន្លកផ្កា។ កាលពីដើមជនជាតិចិនបាញ់ថ្នាំតែដើមណាដែលមានសត្វល្អិតស៊ី ដោយប្រើទ្រនុងស្លឹកថ្នាំជក់បុកច្របាច់ក្នុងទឹក ឬមើមក្បៀស ( Stemona ) ហើយគេបាញ់នឹងស្នប់ធ្វើពីឫស្សីពក។

ឆ្នាំទី៤ ដើមម្រេចឡើងដល់ចុងជន្លង់ ត្រូវជា ៤,៥ម។ ពេលនោះវាបញ្ចេញទិដ្ឋភាពដូចជាសរសរមូលមួយហ៊ុំជិតដោយស្លឹកបៃតងស្រងាត់ ប៉ុន្តែខ្យល់ចេញចូល

បានងាយ គេច្រឹបកំពូលខាងលើដោយកាត់ចុងមែកណាដែលធ្លាក់ស្រយាកមកក្រោម។ ចាប់ពីពេលនោះមក គេទុកផ្កាទាំងអស់។ ចំពោះ ការងារថែទាំ និងការបេះផ្លែ ត្រូវមានមនុស្សម្នាក់សម្រាប់ម្រេច ៥០០ដើម ថែមដីដាក់ជី ស្រោចទឹក ប្រព្រឹត្តកម្មផ្លាស់ជន្លង់ដែលបាក់ សម្អាតដី បេះផល។ រដូវចេញផ្កាមានថេរវេលា ១ខែទៅ២ខែ ហើយទំរាំដល់ពេលបេះផ្លែមានរយៈពេល៨-៩ខែ ការបេះផលគឺធ្វើជាបន្ត តាំងពីខែកុម្ភៈ-ចុងខែមេសា គេបេះផល៣សារយ៉ាងតិច ដោយបេះចង្កោមណាដែលមានគ្រាប់លឿងច្រើន បើទុកយូរពេកអាចត្រូវសត្វស្លាបស៊ីច្រើន។

ទិន្នផលជាម្រេចខ្មៅស្ងួតមានប្រហែល ០,៥០០គ.ក្រ ក្នុងឆ្នាំទី៣ ១គ.ក្រ ក្នុងឆ្នាំទី៤ ១,៥០០គ.ក្រ ចាប់ពីឆ្នាំទី៥ ត្រូវជា ៣.៧៥០គ.ក្រ ក្នុង១ហិកតា រហូតដល់ ២០ ឆ្នាំ បន្ទាប់មកទិន្នផលថយចុះវិញរហូតដល់៣០ឆ្នាំ។ ទោះជាយ៉ាងនេះក៏មានចម្ការម្រេចចាស់ជាងនេះដែរ ប៉ុន្តែផ្ទុយទៅវិញ ក្នុងចម្ការដែលទើបបង្កើតថ្មីៗ ដោយសារមានម្រេចងាប់ច្រើនពេក ក៏គេបោះបង់ចោលចម្ការរវាងឆ្នាំទី១០ ឬឆ្នាំទី១២ដែរ។ ទិន្នផលប្រែប្រួលទៅតាមលក្ខណៈអាកាសធាតុ និងការប្រើប្រាស់ជី ពីព្រោះម្រេចធ្វើប្រតិកម្មឆាប់ណាស់ចំពោះការបន្ថែមជី ឬការខ្វះជី ប៉ុន្តែក៏មានការប្រែប្រួលចំពោះដើមនីមួយៗដែរ ដូច្នេះលទ្ធភាពធ្វើការរើសសម្រាំងពូជបាន ពីព្រោះមានដើមម្រេចខ្លះអាចផ្តល់ផលដល់ ៤-៥ គ.ក្រ គ្រាប់ស្ងួត។

## ៦. ការដាំឱ្យឡើងជន្លង់រស់

ក្នុងប្រទេសជាច្រើន ម្រេចត្រូវបានដាំឱ្យឡើងជន្លង់រស់ ដែលជាដំណាំដើមចម ឬពុំមែនជាដំណាំដើមចមឡើយ ក្នុងគ្រប់ករណីជន្លង់រស់នេះផ្តល់ម្លប់ ផ្តល់ជាតិសរីរាង្គ ហើយធ្វើឱ្យដើមម្រេច ស្ថិតនៅក្នុងភាពប្រហាក់ប្រហែលគ្នា និងស្ថានភាពនៃទីកន្លែងធម្មជាតិរបស់វា។

ជន្លង់រស់ដែលល្អ ត្រូវមានគុណភាពផ្សេងៗ ដែលដួលកាលបែរជាផ្ទុយ ការដុះលូតលាស់លឿន ឫសជ្រៅ សំបកសមស្របដល់សេចក្តីត្រូវការ ភាពស៊ូទ្រាំចំពោះការលះមែកជាបន្តបន្ទាប់ កម្ពស់ដើមសមស្រប។

គហេនសាកល្បងចំពាះដីមឈើជាច្រើន បែប ដើមរលួស ដើមខ្នុរ ស្លា កៅស៊ូ សំបួរ ទេស ម្កាក់ ពោន អង្កាញ កៅស៊ូ និងសំបួរ ទេស ផ្តល់លទ្ធភាពល្អប្រសើរជាងគេ លើ ដីក្រហមនៅជប់។ ដើមមន និងស្វាយចន្ទី មិនល្អទេ។







## ៧.ការប្រមូលផលម្រេច

ដំណាំម្រេចផ្តល់ផលចាប់ពីឆ្នាំទី៣ទៅ ក៏ប៉ុន្តែវាអាស្រ័យទៅលើការថែទាំ និង គុណភាពនៃដីដាំដុះនោះ គេក៏អាចប្រមូលផលដំណាំម្រេចបាននៅឆ្នាំទី២ផងដែរ។ ទិន្នផលមានការប្រែប្រួល ទៅតាមអាយុកាលរបស់ម្រេចដែលក្នុងរយៈពេលពី ៣-៨ឆ្នាំ ម្រេចផ្តល់ទិន្នផល មធ្យមពី ៤-១០ គីឡូក្រាមក្នុង១ជន្លង់ ឬពី ១០-២០តោន ក្នុង១

ហិកតាម្រេចស្រស់ ឬស្មើ ២-៤តោន ម្រេចស្ងួត ក្នុង១ហិកតា។ ម្រេចចាប់ពីអាយុ ១២-១៥ឆ្នាំ ទិន្នផលម្រេចស្រស់ទទួលបាន ពី២-២,៥ គីឡូក្រាមក្នុង១ជន្លង់។ ទិន្នផលប្រែប្រួលទៅតាមលក្ខណៈអាកាសធាតុ និងការប្រើប្រាស់ជី ពីព្រោះម្រេច ធ្វើប្រតិកម្មឆាប់ណាស់ចំពោះការបន្ថែមជី ឬការខ្វះជី ប៉ុន្តែក៏មានការប្រែប្រួលចំពោះដើម នីមួយៗដែរ ដូច្នេះលទ្ធភាពធ្វើការរើសសម្រាំងពូជជាការចាំបាច់ ពីព្រោះមានដើមម្រេចខ្លះអាចផ្តល់ផល ដល់ ៤-៥គ.ក្រ គ្រាប់ស្ងួត។ យើងបេះគ្រាប់ម្រេចទុំពេញលេញ យកមកហាលសម្ងួត ដោយកំដៅថ្ងៃ ឬក៏ឡសម្ងួត។ ចំណែកឯការប្រមូលផលម្រេចមានការខុសៗគ្នាទៅតាមតំបន់នីមួយៗ ដូចមានក្នុងតារាងខាងក្រោមៈ

| ខែ<br>ប្រទេស | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា |
|---|---|---|---|---|---|---|---|---|---|---|
| កម្ពុជា | ■ | ■ | ■ | ■ | ■ | | | | | |
| វៀតណាម | | ■ | ■ | ■ | ■ | | | | | |
| ឥណ្ឌា | ■ | ■ | ■ | | | | | | | |
| ឥណ្ឌូនេស៊ី | | | | | | | ■ | ■ | ■ | ■ |
| ប្រេស៊ីល | | | | | | | | ■ | ■ | ■ |
| ម៉ាឡេស៊ី | | | | ■ | ■ | ■ | ■ | | | |
| ស្រីលង្កា | | | | ■ | ■ | ■ | ■ | | | |









## ៨.សត្វល្អិត និងជំងឺ

សត្វល្អិតម៉្យាងមានស្លាប Elasmognatus nepalensis ដែលគេថាខ្លាម្រេចអាចបណ្តាលឱ្យមានការខូចខាតយ៉ាងច្រើន។ សត្វពេញវ័យរស់នៅក្រោមស្លឹក ហើយដង្កូវរបស់វាស៊ីចាក់ចូលក្នុងពន្លកផ្កា បណ្តាលឱ្យផ្កានោះខះ រហូតនាំឱ្យចង្កោម ផ្កាទាំងមូលរង្គោះជ្រុះ។ដើម្បីប្រឆាំងនឹងខ្លាម្រេចពីដើមជនជាតិចិនបាញ់ថ្នាំផ្សំឡើងដោយទ្រនុងស្លឹកថ្នាំជក់ ឬ មើមក្បៀស។ គេអាចបន្ថយព្រមគ្នាតែម្តងនូវការរាតត្បាតរបស់ខ្លាម្រេច និងចំនួននៃការបាញ់ថ្នាំ ដោយបេះចោលផ្កា ដែលដុះក្រោយរដូវបេះផល បន្ទាប់មកដោយដាក់ជីតែម្តង ក្នុងខែឧសភា។ សត្វកំពូងម៉្យាងតូចៗ ពពួក Apoganin ស៊ីស្លឹកនៅពេលយប់ ហើយពេលថ្ងៃវាពួននៅនឹងគល់ម្រេចដែលនៅទីនោះគេងាយចាប់វា ឬសម្លាប់វាដោយថ្នាំសម្លាប់សត្វល្អិត។ សត្វ cochenillos " អណ្តើកមាស ម៉្យាងមានក្រោះ ឬម្សៅលើស្លាប " ជួនកាលមានច្រើននៅលើចង្កោមផ្កា គេសម្លាប់វាដោយថ្នាំ Systemics ។

ជំងឺស្លោកស្រពោន ជាមូលហេតុធំធ្វើឱ្យដំណាំម្រេចឆាប់ងាប់តាំងពីនៅតូច។ បញ្ហារបស់វា ដែលមានច្រើនយ៉ាង នាំឱ្យគេស្មានទៅលើការកើតមានតំណាលគ្នា ឬការកើតមានជាបន្តបន្ទាប់នៃភ្នាក់ងារចម្លងជំងឺច្រើនបែប ឬមូលហេតុសរីរូបសាស្ត្រ។ ពីដំបូងគេដាក់កំហុសទៅលើសត្វអន្ទង់តូចៗ ពពួក Tylenchus " ដែលបណ្តាលឱ្យម្រេច " បង់កា " ឡើងពណ៌លឿងៗ " ឬពពួកHeterodera, radicicola និង Hetorodera marioni ដែលបណ្តាលឱ្យកើត " ជំងឺរមាស់ " នៅលើឫសម្រេច។

សត្វល្អិតដូចអន្ទង់តូចៗនេះ ច្រើនតែកើតនៅក្នុងដីសម្បូរខ្សាច់ជូរ ត្រជាក់ គ្មានសរីរាង្គ។ គេប្រយុទ្ធនឹងវាដោយការបង្ហូរទឹកចេញឱ្យស្ងួត ដោយការប្រើប្រាស់ជីដែលមិនបង្កឱ្យកើតអាស៊ីដ។ ។

ជំងឺរលួយគល់ ដែលកើតមានចាប់ពីត្រឹមដីឡើងទៅលើ គឺបណ្តាលមកពីផ្សិតម្យ៉ាង:Phytophtora palmivora។ ម្រេចកំចាយ ពូជស្លឹកតូចស៊ូទ្រាំបានប្រសើរជាងពូជស្លឹកធំ ប្រភេទម្រេច " បេឡង់តឹង " ពីប្រទេសថ្វាមានកេរ្តិ៍ឈ្មោះល្បីថាស៊ូទ្រាំបានប្រសើរជាងទៅទៀត ដូច្នេះគេអាចមានលទ្ធភាពដាំវាដោយផ្សាំមែក ឬប្រើប្រាស់វាជាគល់សម្រាប់ទទួលមែកសាក។ ដោយខ្វះខាតមធ្យោបាយមានប្រសិទ្ធភាពសម្រាប់ប្រឆាំង និងជំងឺស្លោកស្រពោន គេមានតែប្រុងប្រយ័ត្នពីដំបូង ដោយប្រើបច្ចេកទេសក្បេត្រសាស្ត្រដាំម្រេច ដូចជា ត្រូវរៀបចំដីបានស្អាតល្អ រចនាសម្ព័ន្ធសមស្រប ។







## ៩. បច្ចេកវិទ្យា

គ្រាប់ម្រេចមានធាតុគីមី ៣ក្រុម ក្នុងបរិមាណខុសៗគ្នា ទៅតាមជាលិកាផ្សេងៗ

- ជាតិ " អាល់កាឡូអ៊ីដម៉្យាង ហៅថាជាតិម្រេច " La piperine ក្នុងក្រុមជាមួយ " នីកូទីន " ដែលផ្តល់រសជាតិហឹរ
- ប្រេងម្រេច ដែលផ្តល់រសជាតិក្រអូបប្រហើរ
- ជ័រម៉្យាងដែលផ្តល់រសជាតិចត់និងហឹរ។

ការបែងចែកធាតុផ្សំទាំងនេះ ប្រែប្រួលទៅតាមគ្រាប់ម្រេចទាំងមូល" ម្រេចខ្មៅ" ឬទៅតាមគ្រាប់គ្មានសំបក" ម្រេចស" :

| | ម្រេចខ្មៅ | ម្រេចស |
|---|---|---|
| Piperine | ៥,០-៩,០ ភាគរយ | ៥,០-៧,០ ភាគរយ |
| Essence du poivere | ០,៦-២, ៣ ភាគរយ | ០,៥-១,៥ ភាគរយ |
| Oleoresine | ០,៨-២,០ ភាគរយ | ០,៧-២,០ ភាគរយ |

ក្នុងពាណិជ្ជកម្ម គេឃើញមានម្រេច ៣បែបៈ នៅក្នុងប្រទេសមានម្រេចខ្ចី ក្នុងការនាំចេញ មានម្រេចខ្មៅ ម្រេចស និងម្រេចក្រហម។ មួយខែឬពីរខែ មុនទុំ " ខែវិច្ឆិកា - ធ្នូ " ផ្លែម្រេច បៃតង ជាគ្រឿងទេសពុំសូវហឹរ ប៉ុន្តែក្រអូប ដែលគេប្រើប្រាស់ផ្សំធ្វើម្ហូបអាហារៈ ឆាក្តាម ឬទាទឹម។ គេប្រឡេះគ្រាប់ត្រាំទឹកខ្មេះធ្វើអំពីស្រា។ ដើម្បីបានគ្រាប់ម្រេចខ្មៅ គេគ្រាន់តែហាលផ្លែម្រេចទាំងចង្កោមឱ្យបានច្រើនថ្ងៃ រួចបែននឹងជើងហើយរែង ក្នុងពេលហាលសម្ងួត ផ្នែកខាងក្រៅនៃសំបកគ្រាប់ឡើងជ្រួញ និងឡើងខ្មៅ ១០០គ.ក្រ ផ្លែម្រេចស្រស់ទាំងចង្កោមផ្តល់ ៣៥គ.ក្រ គ្រាប់ម្រេចខ្មៅស្ងួត។ ចំពោះការនាំចេញគ្រាប់ម្រេចខ្មៅ ត្រូវមានសំណើមតិចជាង ១៥ ភាគរយ និងទម្ងន់យ៉ាងតិច ៤៨០ក្រាមក្នុងមួយលីត្រ។ មួយហាបម្រេច រង្វាស់រង្វាល់ជាប្រពៃណី មានទម្ងន់ ៦៣, ៤២០.គ.ក្រ។

គេផលិតម្រេច ស ដោយយកម្រេចខ្មៅទៅបក់ ឬរែងយកគ្រាប់ធំៗ គេយកគ្រាប់ធំៗ នេះទៅច្រកបាវត្រាំទឹកសាប ឬប្រែបន្តិចៗ អស់រយៈពេល១០ទៅ១៥ថ្ងៃ។

សំបករីកហើយរលួយ។ គេច្របាច់លាងឱ្យជ្រះសំបកនេះ ហើយហាលឱ្យស្ងួត គឺ ម្រេច ស។ ទម្ងន់របស់វា គឺត្រូវមានលើសពី៦៥០ក្រ ក្នុងមួយលីត្រ។ ១០០គ.ក្រ ម្រេចស្រស់ផ្តល់ ៣៤-៣៦គ.ក្រ ម្រេចខ្មៅ ឬ២៤-២៥ គ.ក្រ ម្រេច ស។ ទិន្នផលម្រេច ស ម្រេចខ្មៅ: ៧០ ភាគរយ។

ម្រេចក្រហមបានមកពីគ្រាប់ក្រហមពេញទំហឹង ហាលឱ្យស្ងួត។ គឺជាម្រេចមានគុណភាពខ្ពស់ គេធ្វើតែបន្តិចបន្តួចសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ ប៉ុន្តែមានគេលក់ម្រេចនេះមួយភាគដែរក្រោមឈ្មោះថា ម្រេចអាចម៍សត្វ។ ម្រេចអាចម៍សត្វពិតប្រាកដបានមកពីម្រេចទុំដែលសត្វស្លាបស៊ីហើយជុះមកវិញ ហើយដែលគេរើសពីក្រោមដើមឈើនៅជិតៗ ចម្ការម្រេច។ ម្រេចនេះមានតិចតួចហើយថ្លៃ ប្រហែលវាមានគុណភាពធ្វើឱ្យកើតតម្រេក។

## ឯកសារយោង:


១. សៀវភៅកសិកម្មនៅកម្ពុជា នាយកដ្ឋានរុក្ខាប្រមាញ់, ១៩៨៧

២. International Pepper Community (IPC), កិច្ចប្រជុំលើទី៤០ ពីថ្ងៃទី៣០ខែតុលាដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២នៅ Colombo, Sri Lanka.

៣. International Pepper Community (IPC), កិច្ចប្រជុំលើទី៤២ ពីថ្ងៃទី២៧- ៣០ ខែតុលាឆ្នាំ២០១៤ នៅ Ho Chi Minh , Vietnam .

៤. ដំណាំម្រេច នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម(កម្មវិធីអភិវឌ្ឍន៍វិស័យកសិម្ម) ឆ្នាំ២០០៨

៥. ស្ថិតិដាំដុះដំណាំម្រេចរបស់នាយកដ្ឋានដំណាំឧស្សាហកម្ម៕